**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបាត់ដំបង**

**ក្រុមលទ្ធកម្ម**

លេខ : ០០៦ កល.បសក

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការផ្គត់ផ្គង់សម្ភារ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា សម្រាប់ឆ្នាំ២០១៨

ក្រុមលទ្ធកម្មមន្ទីរអប់រំ យុវជន និងកីឡា ខេត្តបាត់ដំបង សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស(គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា ក្រុមលទ្ធកម្មមន្ទីរអប់រំ យុវជននិងកីឡា ខេត្តបាត់ដំបង នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីធ្វើការផ្គត់ផ្គង់ សម្ភារ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា ថវិការដ្ឋឆ្នាំ២០១៨ ជំពូក ៦០ គណនី ៦០០៥ អនុគណនី ៦០០៥៥ ។

ក្រុមលទ្ធកម្មមន្ទីរអប់រំយុវជន និងកីឡា ខេត្តបាត់ដំបង បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅក្រុមលទ្ធកម្មមន្ទីរអប់រំយុវជន និងកីឡា ខេត្តបាត់ដំបង ដែលមានអាសយដ្ឋានផ្លូវលេខ ០៥ ភូមិអូរខ្ចាយ សង្កាត់ព្រែកព្រះស្ដេច ក្រុងបាត់ដំបង ខេត្តបាត់ដំបង: ចាប់ពីថ្ងៃទី..០៦...ខែ..កុម្ភៈ.....ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៥៣ ៩៥២ ៩០៥ ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង១៥:៣០.ថ្ងៃទី.០៧... ខែ..មីនា......ឆ្នាំ ២០១៨។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅមន្ទីរអប់រំ យុវជន និងកីឡា ខេត្តបាត់ដំបង តាមអាសយដ្ឋានខាងលើ វេលាម៉ោង១៥:៣០ថ្ងៃទី០៧..ខែ.មីនា........ឆ្នាំ ២០១៨។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

មន្ទីរអប់រំ យុវជននិងកីឡា ខេត្តបាត់ដំបង រក្សាសិទ្ធិក្នុងការលើកពេលកែប្រែ និង លុបចោលការដេញថ្លៃក្នុងករណីមានភាពមិនប្រក្រតីណាមួយ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃសូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្មមន្ទីរអប់រំ យុវជន និងកីឡា ខេត្តបាត់ដំបង ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

បាត់ដំបង, ថ្ងៃទី ខែ ឆ្នាំ ២០១៨

**ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត**

**និងជាប្រធានក្រុមលទ្ធកម្ម**

**ចឺ_សែត**

<u>ចម្លងជូន៖</u>

- -អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- -អង្គភាពប្រឆាំងអំពើពុករលួយ "ដើម្បីជូនជ្រាប"
- -ឯកសារកាលប្បវត្តិ